ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ

លេខ: ០០៤/២២ អរក.អ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី៤ ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិក នៃរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌទាំង១៤ រដ្ឋបាលសង្កាត់ទាំង១០៥ មន្ទីរ-អង្គភាពជំនាញ ជុំវិញរដ្ឋបាលរាជធានីភ្នំពេញ ព្រមទាំងបុគ្គលិកសុខាភិបាលជួរមុខវិស័យឯកជន និងប្រជាពលរដ្ឋ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

**រដ្ឋបាលរាជធានីភ្នំពេញ** សូមជម្រាបជូនដំណឹងដល់លោក-លោកស្រី ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកនៃរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌទាំង១៤ រដ្ឋបាលសង្កាត់ទាំង១០៥ មន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ ព្រមទាំងបុគ្គលិកសុខាភិបាលជួរមុខវិស័យឯកជន និងប្រជាពលរដ្ឋនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញមេត្តាជ្រាបថា ក្នុងគោលបំណងធានាការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ ប្រឆាំងនឹងជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវយុទ្ធសាស្ត្រគន្លឹះជាពិសេសការខិតខំខ្នះខ្នែងស្វែងរកវ៉ាក់សាំងការពារជំងឺកូវីដ-១៩និងការដាក់ចេញវិធានការជំរុញ និងបង្កើនល្បឿនការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទាំងដូសមូលដ្ឋាននិងដូសជំរុញ ដើម្បីការពារអាយុជីវិតរបស់ប្រជាជន។

ក្នុងន័យនេះ ដោយទទួលបានការប្រគល់ភារកិច្ចពីគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) និងអនុវត្តតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** **អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងរាជធានីភ្នំពេញ** និងដំណើរការ ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី៤ ជូនដល់លោក-លោកស្រី ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកនៃរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌទាំង១៤ រដ្ឋបាលសង្កាត់ទាំង១០៥ មន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ ព្រមទាំងបុគ្គលិកសុខាភិបាលជួរមុខវិស័យឯកជន និងប្រជាពលរដ្ឋដែលបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ ហើយមានគម្លាតចាប់ពី៤ខែឡើង បន្ទាប់ពីការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ **ចាប់ពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ ខាងមុខនេះ នៅទីតាំងដែលបានកំណត់ជូនក្នុងតារាងឧបសម្ព័ន្ធ ស្របតាមកាលបរិច្ឆេទដូចខាងក្រោម៖**

| ល.រ | ឈ្មោះស្ថាប័ន និងអង្គភាព | កាលបរិច្ឆេទ |
|---|---|---|
| ០១ | មន្ត្រីសុខាភិបាលរាជធានីភ្នំពេញ | **ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២** |
| ០២ | ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកនៃរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌទាំង១៤ រដ្ឋបាលសង្កាត់ទាំង១០៥ | **ថ្ងៃទី១៤ ដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២២** |
| ០៣ | មន្ទីរ-អង្គភាពជុំវិញរដ្ឋបាលរាជធានីភ្នំពេញ | **ថ្ងៃទី១៦ ដល់ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២** |



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

| | | |
|---|---|---|
| ០៤ | ស្នងការនគរបាលរាជធានីភ្នំពេញ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដី | ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ |
| ០៥ | រដ្ឋាករស្វយ័តរថយន្តក្រុង គណៈកម្មការផ្សាររដ្ឋក្នុងរាជធានីភ្នំពេញ និង បុគ្គលិកសុខាភិបាលឯកជន | ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២ |
| ០៦ | មន្ត្រីជួរមុខដែលខកខានមិនទាន់បានចាក់តាមកាលបរិច្ឆេទខាងលើ | ថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ |
| ០៧ | ប្រជាពលរដ្ឋដែលមានអាយុ ៦០ឆ្នាំឡើង | ថ្ងៃទី២១ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ |
| ០៨ | ប្រជាពលរដ្ឋដែលមានអាយុ ១៨ឆ្នាំឡើង | ថ្ងៃទី០១ ដល់ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ |

ចំពោះឯកសារតម្រូវចាំបាច់ដែលត្រូវភ្ជាប់មកជាមួយ រួមមាន (១) ប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ (២) ប័ណ្ណសម្គាល់ខ្លួនមន្ត្រីរាជការ-បុគ្គលិក **និង** (៣) អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ ឯកសារដែលបានប្រើប្រាស់ក្នុងការចាក់វ៉ាក់សាំងដូសទី១ ព្រមទាំងត្រូវគោរពនូវលក្ខខណ្ឌនៃការទទួលបានវ៉ាក់សាំងដូសទី៤ ពោលគឺជានានូវគម្លាតរយៈពេល ០៤ (បួន) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំងដូសជំរុញ ឬដូសទី៣។

ទន្ទឹមនឹងនេះ **រដ្ឋបាលរាជធានីភ្នំពេញ** សូមក្រើនរំលឹក និងអំពាវនាវដល់លោក-លោកស្រីដែលអញ្ជើញទៅទទួលយកវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី៤ ត្រូវប្រកាន់ខ្ជាប់ឲ្យបានជាដាច់ខាតនូវការរក្សាគម្លាតសុវត្ថិភាពសង្គម ពាក់ម៉ាស តម្រង់ជួរ ហើយសូមចូលរួមអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល និងត្រូវប្រកាន់ខ្ជាប់នូវវិធានការ "៣ ការពារ និង ៣ កុំ" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមលោក-លោកស្រី ដែលជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកនៃរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌទាំង១៤ រដ្ឋបាលសង្កាត់ទាំង១០៥ និងមន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ ព្រមទាំងបុគ្គលិកសុខាភិបាលជួរមុខវិស័យឯកជន និងប្រជាពលរដ្ឋនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តការងារនេះ ឲ្យមានប្រសិទ្ធភាព និងទទួលលទ្ធផលល្អប្រសើរ។៚

ថ្ងៃ...ពុធ...១០កើត...ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី...១២.....ខែមករា ឆ្នាំ២០២២
**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- គ.វ.ក-១៩

*-ដើម្បីគោរពជូនជ្រាប-*

- រដ្ឋបាលខណ្ឌទាំង១៤
- មន្ទីរ-អង្គភាពជុំវិញរដ្ឋបាលរាជធានីភ្នំពេញ

*-ដើម្បីអនុវត្ត-*

- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ

*-ដើម្បីផ្សព្វផ្សាយ-*

- ឯកសារ-កាលប្បវត្តិ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ

# ឧបសម្ព័ន្ធ

## ស្តីពី

## ទីតាំងចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី៤ ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ មន្ត្រីសុខាភិបាល និងបុគ្គលិក នៃរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌទាំង១៤ រដ្ឋបាលសង្កាត់ទាំង១០៥ មន្ទីរ-អង្គភាពជំនាញ ជុំវិញរដ្ឋបាលរាជធានីភ្នំពេញ ព្រមទាំងមន្ត្រីសុខាភិបាលជួរមុខវិស័យឯកជន និងប្រជាពលរដ្ឋ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

ចាប់ពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២

ពេលព្រឹក ម៉ោង ០៨:០០ ដល់ ១១:០០

ពេលរសៀល ម៉ោង ១៤:០០ ដល់ ១៧:០០

| ល.រ | ឈ្មោះមូលដ្ឋានខណ្ឌ | ទីតាំងចាក់វ៉ាក់សាំង | អ្នកសម្របសម្រួល |
|---|---|---|---|
| ១ | **៧មករា** | **មាន ០២ ទីតាំង៖**<br>១.មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ<br>២.មន្ទីរសម្រាកព្យាបាលអូឡាំព្យា មេនីខល | ០១២ ៨៣២ ២០៧<br>០១២ ៩០៧ ៩២៦<br>០១៧ ២៣៦ ៧៦៧ |
| ២ | **ដូនពេញ** | **មាន ០១ ទីតាំង៖**<br>១.មន្ទីរពេទ្យបង្អែកចតុមុខ | ០១៧ ៨៨៤ ៨៨៨<br>០៨១ ៣៦៨ ៩៩៩<br>០៨៨ ៨៨៥៨ ៨៩៩ |
| ៣ | **ទួលគោក** | **មាន ០៣ ទីតាំង៖**<br>១.មណ្ឌលសុខភាពទួលគោក<br>២.វត្តនាគវ័ន (មុខសាលាពុទ្ធិក)<br>៣.វត្តនាគវ័ន (ក្រោយសាលាធាន់) | ០១៧ ៣៨៨ ៩៨៨<br>០១២ ៨១៥ ៧៧៦<br>០៨៩ ៥៧៨ ៦៧១ |
| ៤ | **មីងជ័យ** | **មាន ០១ ទីតាំង៖**<br>១.មណ្ឌលសុខភាពទួលស្វាយព្រៃ | ០១១ ៨៣៨ ៣៦៧<br>០១២ ៩៣៦ ៨៦៦<br>០១៧ ៩៥៩ ៦២៣ |
| ៥ | **ចំការមន** | **មាន ០២ ទីតាំង៖**<br>១.មណ្ឌលសុខភាពផ្សារដើមថ្កូវ<br>២.កោះពេជ្រ | ០១១ ៩៨៨ ៨៨៧<br>០១២ ៤៥៦ ២២២<br>០១២ ៥៥៨ ៧៧៧ |
| ៦ | **ជ្រោយចង្វារ** | **មាន ០៣ ទីតាំង៖**<br>១.មណ្ឌលសុខភាពកោះដាច់<br>២.មណ្ឌលសុខភាពជ្រោយចង្វារ<br>៣.ផ្សារ OCIC | ០១២ ៦៩៤ ៥៦៥<br>០៩២ ២៥០ ៣៤៥<br>០១៧ ៦៩៩ ៥៥៥ |



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

| | | | |
|---|---|---|---|
| ៧ | **ឫស្សីកែវ** | មាន ០២ ទីតាំង៖<br>១.មន្ទីរពេទ្យបង្អែកសម្តេចឪ-សម្តេចម៉ែ<br>២.មណ្ឌលសុខភាពគីឡូម៉ែត្រលេខ៩ | ០១២ ៦៣៣ ៤៣៤<br>០១២ ២៦២ ៩០៦<br>០៨៥ ៥៥៥ ៩៥០ |
| ៨ | **ពោធិ៍សែនជ័យ** | មាន ០៧ ទីតាំង៖<br>១.មណ្ឌលសុខភាពសំរោងក្រោម<br>២.មណ្ឌលសុខភាពសាមគ្គី<br>៣.មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង<br>៤.រោងចក្រសួនកាណាឌីយ៉ា<br>៥.រោងចក្រ SIS<br>៦.វត្តគោកបញ្ជាន់<br>៧.វត្តជម្ពូវ័ន | ០១២ ៤០១ ៦១៦<br>០១២ ៩១៨ ១៨២<br>០១២ ៥៦៥ ៣៥៣ |
| ៩ | **កំបូល** | មាន ០៥ ទីតាំង៖<br>១.មណ្ឌលសុខភាពស្គោរ<br>២.មណ្ឌលសុខភាពឪឡោក<br>៣.មណ្ឌលសុខភាពប្រទះឡាង<br>៤.មណ្ឌលសុខភាពបឹងធំ<br>៥.មណ្ឌលសុខភាពកំបូល | ០១២ ៣៤៧ ៦៧៦<br>០៨៩ ៥៩៨ ៥៩៨<br>០១១ ៤០១ ៦១៧<br>០៦៩ ៥៦៥ ៦៩៩ |
| ១០ | **ច្បារអំពៅ** | មាន ០៥ ទីតាំង៖<br>១.មន្ទីរពេទ្យបង្អែកច្បារអំពៅ<br>២.មណ្ឌលសុខភាពនិរោធ<br>៣.មណ្ឌលសុខភាពព្រែកឯង<br>៤.មណ្ឌលសុខភាពក្បាលកោះ<br>៥.មណ្ឌលសុខភាពព្រែកថ្មី | ០១៧ ៧៦៧ ៦១៧<br>០១២ ៤៨៣ ៦៨៣<br>០១២ ៨៤៦ ៣៧៧ |
| ១១ | **មានជ័យ** | មាន ០៤ ទីតាំង៖<br>១.មន្ទីរពេទ្យបង្អែកច្បារអំពៅ<br>២.មណ្ឌលសុខភាពស្ទឹងមានជ័យ<br>៣.អតីតរោងចក្រស្លុតវ៉ែរ<br>៤.វត្តនន្ទមុនី | ០១២ ៥៥៥ ៥៨១<br>០១២ ៩៧៧ ៨៦៤<br>០១២ ៩៧៥ ៤៦០ |
| ១២ | **សែនសុខ** | មាន ០៥ ទីតាំង៖<br>១.មន្ទីរពេទ្យបង្អែកមិត្តភាពកម្ពុជា-ចិនសែនសុខ<br>២.មណ្ឌលសុខភាពឃ្មួញ<br>៣.មណ្ឌលសុខភាពក្រាំងធ្នង់<br>៤.មណ្ឌលសុខភាពភ្នំពេញថ្មី<br>៥.មណ្ឌលសុខភាពទឹកថ្លា | ០១២ ២១៦ ២១៦<br>០១២ ៧៣៧ ៣១៦<br>០១២ ៩៣១ ៧៦៩ |
| ១៣ | **ដង្កោ** | មាន ០៨ ទីតាំង៖<br>១.មន្ទីរពេទ្យបង្អែកដង្កោ<br>២.មណ្ឌលសុខភាពជើងឯក<br>៣.មណ្ឌលសុខភាពសាក់សំពៅ<br>៤.មណ្ឌលសុខភាពព្រែកកំពឹស<br>៥.មណ្ឌលសុខភាពល្វេស<br>៦.មណ្ឌលសុខភាពពងទឹក<br>៧.មណ្ឌលសុខភាពព្រៃស<br>៨.មណ្ឌលសុខភាពព្រៃវែង | ០១២ ២២៧ ៩១៩<br>០១២ ៥៨៩ ៣៦៥<br>០១២ ៩៣៤ ១៥០ |

| | | | |
|---|---|---|---|
| ១៤ | **ព្រែកព្នៅ** | **មាន ០៤ ទីតាំង៖**<br>១.មន្ទីរពេទ្យបង្អែកព្រែកព្នៅ<br>២.មណ្ឌលសុខភាពសំរោង<br>៣.មណ្ឌលសុខភាពពញាពន់<br>៤.មណ្ឌលសុខភាពគោករកា | ០៧៦ ៨០៨ ៩៩៩៩<br>០១២ ៦៤៨ ៤០៣<br>០១៧ ៧៨៧ ៦៨៦<br>០៦៦ ៣៨១ ៧២៧ |

*បញ្ជាក់៖ក្រុមការងារសូមរក្សាសិទ្ធក្នុងការកែសម្រួលទីតាំងទៅតាមស្ថានភាពជាក់ស្តែង។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh